# សុន្ទរកថា
# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស

ថ្ងៃអង្គារ ០៩ រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៩ វេលាម៉ោង ៩:00 នាទីព្រឹក

****

**- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលបរទេសនានា ក្នុងពិធីបើកកិច្ចប្រជុំពិគ្រោះយោបល់នាឱកាសដ៏ថ្លៃថ្លានេះ។ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ ចំពោះវត្តមាន និងភាពសកម្មចូលរួមរបស់សមាជិក សមាជិកា នៃអង្គប្រជុំ។

ត្បិតយើងទើបមានឱកាសជួបប្រជុំគ្នាជាលើកដំបូង ជាផ្លូវការនាពេលនេះ ក្រោយពីការប្រកាសដាក់ឲ្យអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (Law on Associations and Non-Governmental Organizations-LANGO) កាលពីថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៥, ប៉ុន្តែយើងបានបន្តប្រពៃណីនៃកិច្ចសហការគ្នាល្អក្នុងភាពជាដៃគូជាដរាបមក។ ខ្ញុំរំពឹងថា កិច្ចប្រជុំពិគ្រោះយោបល់នាថ្ងៃនេះ នឹងរួមចំណែកលើកកម្ពស់និងពង្រឹងកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលបរទេស (Foreign NGOs) ឲ្យបានកាន់តែល្អប្រសើរថែមទៀត ដើម្បីបម្រើនិងការពារនូវឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជាយ៉ាងពិតប្រាកដ។ វេទិកានេះ ក៏នឹងផ្តល់ឱកាសឲ្យយើងរួមគ្នាកំណត់នូវបញ្ហាប្រឈមនានា និងស្វែងរកដំណោះស្រាយសមស្រប ដើម្បីពង្រឹងការអនុវត្តច្បាប់និងបទបញ្ញត្តិជាធរមាន ឲ្យកាន់តែមានប្រសិទ្ធភាពសក្តិសមជានីតិរដ្ឋ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ខ្ញុំសូមថ្លែងអំណរគុណចំពោះគ្រប់បណ្តាអង្គការមិនមែនរដ្ឋាភិបាលបរទេសទាំងអស់ដែលមានសមានចិត្តនិងសុឆន្ទៈស្មោះសរ ក្នុងការជួយឧបត្ថម្ភគាំទ្រដល់ដំណើរការកសាងជាតិនិងអភិវឌ្ឍន៍ប្រទេសកម្ពុជាក្នុងគ្រប់កាលៈទេសៈដោយឥតលក្ខខណ្ឌ ចាប់តាំងពីគ្រាក្រលំបាក រហូតដល់កម្ពុជាសម្រេចបាននូវសន្តិភាពពេញលេញ, ឯករាជ្យភាព, ការឯកភាពជាតិ, ដំណើរការលទ្ធិប្រជាធិបតេយ្យ និងវឌ្ឍនភាពជាទូទៅលើគ្រប់វិស័យ។

សមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងមក ពិតជាមានការចូលរួមចំណែកមិនអាចខ្វះបានពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះមានវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលទាំងក្នុងស្រុក និងបរទេសបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកផ្តល់សេវា និងគាំទ្រដល់វិស័យសំខាន់ៗដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច សង្គមកិច្ចនៅតាមមូលដ្ឋានជនបទ និងសហគមន៍ដាច់ស្រយ៉ាល នៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាល ប្តេជ្ញាបន្តសហការយ៉ាងជិតស្និទ្ធ និងបើកទ្វារចំហរង់ចាំស្វាគមន៍នូវកិច្ចសហប្រតិបត្តិការ ជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេសទាំងអស់ដែលប្រតិបត្តិដោយសុចន្ទៈនិង ឈរលើឧត្តមគតិនៃការគិតគូរដល់ប្រយោជន៍ប្រជាជនជាធំ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានរៀបចំឡើងក្នុងគោលបំណងការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងផលប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជាឲ្យមានការរីកចម្រើនលើគ្រប់វិស័យ ដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ នៃច្បាប់នេះ។ វាជាការបើកទំព័រសករាជថ្មី នៃភាពជាដៃគូដែលឈរលើមូលដ្ឋាននិងគោលការណ៍នៃការគោរពគ្នាទៅវិញទៅមក, ការគោរពនូវភាពជាម្ចាស់នៃដោគវាសនាប្រទេសខ្លួន និងអធិបតេយ្យភាពជាតិ នៅក្នុងបរិការណ៍នៃប្រទេសជាតិមួយដែលបាននិងកំពុងខិតខំកសាងនិងពង្រឹងនីតិរដ្ឋ ឧត្តមភាពជាតិ និងវិបុលភាពរបស់ប្រជាជនខ្លួន។ ម្យ៉ាងវិញទៀត ច្បាប់នេះក៏បានបង្កើតនូវក្របខ័ណ្ឌ និងមូលដ្ឋានគ្រឹះគតិយុត្តិមួយជាក់លាក់ ច្បាស់លាស់សម្រាប់តួអង្គពាក់ព័ន្ធងាយស្រួលក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន និងជានាអនុលោមភាព។ ការគោរពបានទាំងស្រុងនូវច្បាប់នេះ នឹងធានាបាននូវប្រសិទ្ធិភាព សក្តិភាព ភាពជឿជាក់ និងនិរន្តរភាពយូរអង្វែងនៃភាពជាដៃគូក្នុងការរួមចំណែកកសាងនិងអភិវឌ្ឍន៍កម្ពុជា ឲ្យសម្រេចបាននូវគោលដៅរបស់ខ្លួនជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ រាជរដ្ឋាភិបាលកម្ពុជា តែងប្រកាន់ខ្ជាប់នូវគោលការណ៍នៃការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ហើយតែងឲ្យតម្លៃជានិច្ចដល់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដែលជាផ្នែកមួយដំណើរការលទ្ធិប្រជាធិបតេយ្យ។ ក្នុងនាមជារដ្ឋអធិបតេយ្យ និងជាអង្គដែលទទួលបានអាណត្តិស្របច្បាប់តែមួយគត់ពីប្រជាពលរដ្ឋម្ចាស់ឆ្នោតក្នុងការដឹកនាំ, រាជរដ្ឋាភិបាលមានបំណងប្រាថ្នាតែមួយគត់គឺរួមគ្នាធ្វើយ៉ាងណាឲ្យការចូលរួមទាំងនោះប្រព្រឹត្តទៅដោយការគោរពគ្នាទៅវិញទៅមកនូវអាណត្តិកិច្ច និងស្ថិតត្រឹមដែនកំណត់នៃសិទ្ធិ ក្នុងកិច្ចប្រតិបត្តិការរៀងៗខ្លួន។

ខ្ញុំសូមបញ្ជាក់ជូនថា ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល បានកំណត់យ៉ាងច្បាស់អំពីសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ និង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក (Local Associations/NGOs) ត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ហើយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

បរទេស (Foreign Associations/NGOs) ត្រូវចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមទម្រង់អនុស្សរណៈនៃការយោគយល់គ្នា (MoU)។ MoU រវាងក្រសួងការបរទេសជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស មានសុពលភាព ៣ (បី)ឆ្នាំ និងអាចបន្តសុពលភាពបាន។ ក្រោយច្បាប់នេះចូលជាធរមាន ក្រសួងបានធ្វើការកែតម្រូវខ្លឹមសារនៃ **MoU គំរូចាស់** ឲ្យស្របតាមខ្លឹមសារនៃច្បាប់ និងបានអនុវត្ត **MoU គំរូថ្មី** ចាប់ពីខែមករា ឆ្នាំ២០១៦ ព្រមទាំងបានទទួលចុះ MoU ជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេសថ្មីចំនួន**៦៥** បន្ថែមទៀត។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ មានអង្គការមិនមែនរដ្ឋាភិបាលបរទេសចំនួន **៣៨៦** នៅមានសុពលភាព ហើយអង្គការមិនមែនរដ្ឋាភិបាលបរទេសទាំងនោះមកពីប្រទេសផ្សេងៗនៃទ្វីបអាស៊ី អាមេរិក អឺរ៉ុប និងអូស្ត្រាលី ដែលមានគម្រោងសំខាន់ៗផ្តោតលើវិស័យៈ អប់រំ សុខាភិបាល សង្គមកិច្ច កសិកម្ម បណ្តុះបណ្តាល វិជ្ជាជីវៈ អភិវឌ្ឍន៍សហគមន៍ បរិស្ថាន និងបោសសម្អាតមីន។

រាជរដ្ឋាភិបាលបានជ្រាបនិង យល់ច្បាស់នូវក្តីបារម្ភនិងក្តីកង្វល់របស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិសេរីភាពក្នុងការបំពេញការងាររបស់ខ្លួននៅមូលដ្ឋាន នៅក្នុងបរិបទនៃក្របខ័ណ្ឌច្បាប់ថ្មី។ ជាការពិត កិច្ចដំណើរការអភិវឌ្ឍនិងការពង្រឹងនីតិរដ្ឋ អធិបតេយ្យភាព និងភាពជាម្ចាស់ក្នុងការដឹកនាំប្រទេស រមែងនាំមកនូវការផ្លាស់ប្តូរបរិបទ ក៏ដូចជាលំអាននិងនិយាមប្រតិបត្តិការមួយចំនួន ដែលតួអង្គពាក់ព័ន្ធធ្លាប់និងស៊ាំរួចទៅហើយៗពុំចង់ ឬមានការលំបាកធ្វើការកែប្រែ។ ប៉ុន្តែខ្ញុំយល់ថា មានតែមូលដ្ឋានច្បាប់និងគតិយុត្តិច្បាស់លាស់ប៉ុណ្ណោះ ដែលជាសរសរស្តម្ភរឹងមាំទ្រទ្រង់ឲ្យកិច្ចសហប្រតិបត្តិការរបស់យើង អាចមានអាយុកាលយូរអង្វែង ប្រកបដោយភាពសុខដុម និងជោគជ័យ។ ច្បាប់នេះ មិនត្រូវបានធ្វើឡើងដើម្បីរឹតត្បិតអង្គការណាមួយទេ ប៉ុន្តែច្បាប់នេះនឹងតម្រូវឲ្យអង្គការទាំងអស់ ប្រតិបត្តិការប្រកបដោយតម្លាភាព គណនេយ្យភាព សុចរិតភាព និងការទទួលខុសត្រូវចំពោះមុខច្បាប់។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

ខ្ញុំក៏សូមអំពាវនាវដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាដៃគូរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវបន្តសហការ សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់អង្គការដែលនៅមានសុពលភាព MoU ជាមួយក្រសួងការបរទេស ក្នុងកិច្ចប្រតិបត្តិការសកម្មភាពរបស់ពួកគាត់។ ទន្ទឹមនេះ សូមអង្គការមិនមែនរដ្ឋាភិបាលបរទេសទាំងអស់ អនុវត្តសកម្មភាពរបស់ខ្លួនឲ្យស្របតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។ លើសពីនេះទៀត សូមជៀសវាងជាដាច់ខាតនូវសកម្មភាពទាំងឡាយណាដែលអាចជាប់ពាក់ព័ន្ធ ឬគាំទ្រដល់ការលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានអាវុធមហាប្រល័យ ដែលបានកំណត់ឡើងដោយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ ដើម្បីជៀសផុតពីការធ្លាក់ចូលទៅក្នុងបញ្ជីប្រផេះរបស់ស្ថាប័ននេះ និងកុំឲ្យមានជាបច្ច័យអវិជ្ជមានដល់កម្ពុជាយើងលើផ្នែកប្រព័ន្ធហិរញ្ញវត្ថុ លំហូរវិនិយោគ និងនយោបាយជាដើម។ ទន្ទឹមនឹងនេះ សូមអង្គការមិនមែនរដ្ឋាភិបាលបរទេសទាំងអស់ ធ្វើប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួនតាមប្រព័ន្ធធនាគារដែលស្របច្បាប់ និងមានអាជ្ញាប័ណ្ណផ្លូវការចេញដោយធនាគារជាតិ នៃកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវក្នុងការងារកន្លងមករបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្រុមមន្ត្រីជំនាញដែលទទួលបន្ទុកការងារអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានរៀបចំកិច្ចប្រជុំថ្ងៃនេះ។ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកានៃអង្គប្រជុំទាំងមូល សូមជួបប្រទះតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស ចាប់ពីពេលនេះតទៅ។

*សូមអរគុណ* !